**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

**ស្តីពី**

# ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០២០

**រវាង**

ក្រុមហ៊ុន **ឃែនធើរនេអឺតែរីល (ខេមបូឌា)** មានទីតាំងស្ថិតនៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យរាជធានីភ្នំពេញតំណាងដោយលោក CHOONG WEIPIAU ចាប់ពីពេលនេះតទៅហៅថា ភាគី "ក"។

**ជាមួយនឹង**

កម្មករនិយោជិតនៃក្រុមក្រុមហ៊ុន **ឃែនធើរនេអឺតែរីល (ខេមបូឌា)** មានទីតាំងស្ថិតនៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញដែលតំណាងដោយ តំណាងកម្មករ ប្រតិភូបុគ្គលិក និង ថ្នាក់ដឹកនាំសហជីព ចាប់ពីពេលនេះតទៅហៅកាត់ថា ភាគី "ខ"។

**ដោយហេតុថា**

១- ដោយហេតុថាៈភាគី"ក"ជួបការលំបាកផ្នែកសេដ្ឋកិច្ច ដោយសារមានការរីករាលដាលជាសកលនៃជំងឺឆ្លង COVID-19 ធ្វើអោយការបញ្ជាទិញថយចុះនិងមានការពន្យាពេលការ ចេញទំនិញដែលនាំឲ្យមិនមានការងារឲ្យកម្មករនិយោជិតធ្វើគ្រប់គ្រាន់។

២- ដោយហេតុថាៈ ភគី "ក" មានបំណងចង់ព្យួរកិច្ចសន្យាការងារ មានចិរៈវេលា ១ (មួយ)ខែ ។

៣- ដោយហេតុថាៈ ភាគី "ក" និងភាគី "ខ" បានពិភាក្សាគ្នា និងបានព្រមព្រៀងគ្នារួចហើយ។

**ក្រោយពីបានពិភាក្សាគ្នាមក ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោមៈ**

**ប្រការ១ៈ ការព្រមព្រៀង**

១.១- ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងព្យួរកិច្ចសន្យាការងារ មានថិរវេលាចំនួន ១(មួយ) ខែ ដោយគិតចាប់ពីថ្ងៃទី ១៦ ខែមេសាឆ្នាំ២០២០ ដល់ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០២០។

១.២- ការព្យួរការងារពាក់កណ្ដាល៥០(ហាសិប)ភាគរយទៅតាមផ្នែកនិមួយៗ

១.៣-ភាគី(ក)ជាអ្នករៀបចំការព្យួរកិច្ចសន្យាការងារនេះតាមផ្នែកនៃសង្វាក់ផលិតកម្មរបស់ក្រុមហ៊ុន ។

**ប្រការ២-ការផ្ដល់ប្រាក់ឧបត្ថម្ភ**

២.១- ភាគី "ក" យល់ព្រមផ្ដល់ប្រាក់ឧបត្ថម្ភដល់ភាគី "ខ" ក្នុង ១ខែស្មើនឹង៤០ (សែសិប) ភាគរយនៃ១៩២ដុល្លាអាមេរិកដែលជាប្រាក់ឈ្នួលអប្បបរមាសម្រាប់ ឆ្នាំ២០២០។

២.២- រាជរដ្ឋាភិបាលផ្ដល់ប្រាក់ឧបត្ថម្ភចំនួន ២០(ម្ភៃ)ភាគរយ នៃ១៩០ ដុល្លាអាមេរិជូនភាគី "ខ"អនុវត្តនតាម(សេចក្ដីណែនាំលេខ០១២/២០ប.ក/ស.ណ.ន.ខ.ល)។

**ប្រការ៣-របៀបបើកប្រាក់ឧបត្ថម្ភ**

៣.១-ភាគី "ក"នឹងបើកប្រាក់ឧបត្ថម្ភជូនភាគី "ខ" តាមសេចក្ដីប្រកាសរបស់ក្រសួងការងារស្ដីពីការបើកប្រាក់ឈ្នួលប្រចាំខែ(លើកទី១នៅថ្ងៃទី១៩និងលើកទី២នៅថ្ងៃទី៧ខែបន្ទាប់) នៅ វេលាម៉ោង ២.៣០(ពីរសាមសិប)នាទីរសៀលតាមខែនិមួយៗ ។

៣.២- ភាគី "ខ" នឹងទទួលប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលអនុវត្តនតាម (សេចក្ដីណែនាំលេខ ០១២/២០ប.ក/ស.ណ.ន.ខ.ល ) ។

**ប្រការ៤- អវសានប្បញ្ញត្តិ**

៤.១-ភាគីទាំងពីរបានអាននិងយល់ច្បាស់គ្រប់ប្រការដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះហើយភាគីទាំងពីរបានឯកភាពគ្នាចុះហត្ថលេខាដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។

៤.២- កិច្ចព្រមព្រៀងនេះធ្វើឡើងជាភាសាខ្មែរ ចំនួន០៣ច្បាប់ ដោយរក្សាទុកនៅ៖

-ភាគី "ក" ចំនួន ០១ (មួយ) ច្បាប់។

-ភាគី "ខ" ចំនួន ០១ (មួយ) ច្បាប់។

-ការិយាល័យមេធាវី ចំនួន ០១ (មួយ) ច្បាប់។

-ភាគី "ខ" ចំនួន ០១ (មួយ) ច្បាប់។

-ការិយាល័យមេធាវី ចំនួន ០១ (មួយ) ច្បាប់។

៤.៣កិច្ចព្រមព្រៀងនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខារបស់ភាគីទាំងពីរតទៅ។

៤.៤ ភាគីទាំងពីរព្រមព្រៀងចាត់ទុកជាមោឃៈនូវរាល់កិច្ចព្រមព្រៀងកន្លងមកទោះបីជាបាន ធ្វើជាលាយលក្ខអក្សរឬពាក្យសំដីក្ដី។

**តំណាងភាគី "ក"**

CHOONG WEI MING

**តំណាងភាគី "ខ"**

បានឃើញ និងបញ្ជាក់ថា

ភាគីទាំងពីរពិតជាបានចុះហត្ថលេខា នៅចំពោះមុខមេធាវី។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០

**ហត្ថលេខា និងត្រា**

**មេធាវី**

AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី **ហំ_ភា**